## កម្រង អត្ថបទ ធម៌ទេសនា

## ស្ដីអំពី

# “ខ្លឹមសារ..”

ភិក្ខុ កែវ-អ៊ុន ឬ សំអៀន

“ អភិញ្ញានសីលោ ”

វត្ត សម្ដេចព្រះមហាឃោសានន្ទ

“ មជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរអន្តរជាតិ”

ទីក្រុងអូកឡិនដ៍ រដ្ឋកាលីហ្វ័រនីញ៉ា

សហរដ្ឋ អាមេរិក

ថ្ងៃចន្ទ៨កើតផល្គុន,ឆ្នាំម្សាញ់បញ្ចស័ក ព.ស.២៥៥៦; ២៩មីនា គ.ស.២០១៣

សូមលោកអ្នក មេត្តានឹកឈ្មោះខ្ញុំ,ហើយឧទ្ទិសកុសលឲ្យដល់ខ្ញុំ

## អារម្ភកថា

ខ្ញុំបានតាក់តែងរៀបរៀងអត្ថបទធម៌ទេសនានេះឡើងដើម្បីសម ដល់ធម្មកថិកថ្មីដែលទើបចាប់ផ្តើមរៀនទេសនាជាដំបូង,អានហើយ អានទៀតៗឲ្យចាំគោលសេចក្តីល្អម ហើយបន្ថែមបន្ថយខ្លះៗទៅក៏ អាចទេសនាបានហើយ!ព្រោះខ្ញុំធ្វើអត្ថបទនិមួយៗឲ្យខ្លីល្មម ដើម្បី ធម្មកថិកថ្មីសិក្សា, បើមិនចាំបានទាំងអស់, ក៏គង់ចាំបានគោលធម៌ សេចក្តីល្មមតែអាចទេសន៍១គ្រែបានដែរ។ ឯខ្លួនខ្ញុំក៏មិនមែនជាធម្ម កថិកអ្នក"ពូកែ" ខាងទេសនានោះទេ!ខ្ញុំគ្រាន់តែសិក្សារៀនសង្កេត តាមលំនាំឃ្លោងឃ្លានិងសំនួនវោហារបស់ធម្មកថិកដែលល្បីៗដែល លោកមានជំនាញខាងការសំដែងធម៌ទេសនាហើយ ខ្ញុំក៏សាកល្បង រៀនសរសេរជាអត្ថបទធម៌ទេសនានេះឡើងប៉ុណ្ណោះ អាស្រ័យហេតុ នេះខ្ញុំសូមផ្ញើសេចក្តីសង្ឃឹមដ៏កក់ក្តៅលើ លោកជាបណ្ឌិតអត្ថកោវិទ ឬកវីនិពន្ធដ៏ប្រសើរៗនិងធម្មកថិកាចារ្យទាំងឡាយមេត្តាជួយកែសំរួល នូវរាល់កំហុសឆ្គងបើមាន,ដែលហួសពីសមត្ថភាពរបស់ខ្ញុំដោយសេច ក្តីអនុគ្រោះផង។

សូមអរគុណ

= = = = = o o o = = = = =

# សេចក្តីអនុញ្ញាត និងអធិដ្ឋាន

មហាឧបាសិកាសុខ-ឈុនលី ព្រមទាំងកូនចៅនៅទីក្រុងអូកឡិនដ៍ រដ្ឋកាលីហ្វ័រនីញ៉ា សហរដ្ឋអាមេរិក មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាមុតមាំណាស់!បានកសាង”សមិទ្ធិផល”ជាច្រើនកប់ទុកក្នុងព្រះពុទ្ធសាសនាមានសមិទ្ធិផលក្នុង“មជ្ឈមណ្ឌលធម្មទូត”នៅស្រុកលើកដែក ខេត្តកណ្តាលប្រទេសកម្ពុជាជាដើមនិងបានកសាងនៅឯ “ពុទ្ធភូមិ”ប្រទេសឥណ្ឌាឯណោះថែមទៀតផង។ មហាឧបាសិកាបានដង្ហែ “កឋិន” ជារៀងរាល់ឆ្នាំ,មិនតែប៉ុណ្ណោះមហាឧបាសិកាមានចេតនាចង់បំពេញកុសលជាធម្មទានទៀត ទើបបានមកសុំពីខ្ញុំនូវ “កម្រងអត្ថបទធម៌ទេ-សនា”នេះយកទៅបោះពុម្ពចែកផ្សាយជាធម្មទាន,ខ្ញុំក៏មានមោទនភាពណាស់!បានអនុញ្ញាតឲ្យមហាឧបាសិកាយកទៅបោះពុម្ពចែកជាលើកទី២ហើយខ្ញុំបានដកអត្ថបទធម៌ខ្លះចេញ! ដើម្បីឲ្យសៀវភៅស្តើងជាងមុនដោយអំណាចមហាផលានិសង្សនៃមហាកុសលធម្មទាននេះ សូមឲ្យយើងខ្ញុំមានជោគជ័យដ៏ត្រចះត្រចង់ក្នុងឆាកជីវិតនៃជាតិនេះផងនិងទៅក្នុងអនាគតជាតិ សូមឲ្យយើងខ្ញុំបានស្តាប់ធម៌ ព្រះសិអារ្យមេត្រីយ៍ ហើយបានសម្រេចធម៌ជាន់ខ្ពស់បានផុតចាកទុក្ខទាំងពួងកុំបីខាន! ៕

ក្រុងអូកឡិនដ៍ ថ្ងៃចន្ទ៧កើតខែផល្គុន,ឆ្នាំម្សាញ់បញ្ចស័ក ព.ស.2556

ត្រូវនិងថ្ងៃទី១៨មីនា 2013 ៕

# ឧទ្ទិសកថា

ដោយអំណាចនៃមហាកុសលចេតនាចិត្តឲ្យខ្ញុំមានបីតិសោមនស្ស ដ៏ខ្ពង់ខ្ពស់បំផុត!ក្នុងព្រះពុទ្ធសាសនា ក្នុងការសរសេរអត្ថបទធម៌នេះ មិនថាថ្ងៃឬយប់ សូម្បីសុខភាពពុំបរិបូណ៌ដោយជរាពាធវាបៀតបៀន សរីរាងខ្ញុំយ៉ាងណាក៏ដោយ! ក៏ឆន្ទៈនៃខ្ញុំដែលផុះផុរឡើង ចំពោះព្រះធម៌វាឡើងដល់ថ្នាក់កំពូលបានជំរុញទឹកចិត្តខ្ញុំ ឲ្យខំពុះពារជម្នះគ្រប់ឧបស័គ្គដរាបឲ្យខ្ញុំបានសំរេចនូវកិច្ចដ៏ពិសេសនេះជាស្ថាពរទោះបីពុំមានភាពប្រសើរឧត្តុង្គឧត្តមយ៉ាងណានោះក៏ដោយ។ ដោយអំណាចមហាផលានិសង្សដ៏ប្រសើរនេះខ្ញុំសូមបូជាចំពោះ= គុណលោកបិតានាម កែវ-ម៉ិញ ,មាតានាមកែរ-អឹម,ដែលបានផ្តល់កំណើតនិងចិញ្ចឹម-ថែរក្សាខ្ញុំឲ្យ“រស់ ”និងឲ្យបានរៀនសូត្ររហូតមក!។ = គុណព្រះពុទ្ធសាសនាដែលបានបង្ហាញផ្លូវខ្ញុំឲ្យយល់ត្រូវឲ្យដើរផ្លូវត្រូវ !។ = គុណលោកគ្រូទាំងឡាយដែលបានបង្រៀនខ្ញុំ នូវគ្រប់មុខវិជ្ជា!ទាំងពួង ។ = គុណញាតិញោម!ទាំងនៅកម្ពុជានិងនៅ ស.រ.អា. ដែលបានជួយឧបត្ថម្ភខ្ញុំ។ = គុណលោកបិតាក្មេកនាម ម៉ុល-ឯម,លោកមាតាក្មេកនាមខៀវ-សង្វាន។ =គុណឧបាសិកា ខៀវ-សារ៉ាង ឬ ម៉ុល-សំអាង ដែលបានអនុញ្ញាតខ្ញុំឲ្យបានសាងផ្នួស ។ សូមជូនមហាកុសលនេះចំពោះកូនប្រុស កែវ-តារាវុឌ្ឍ, កូនស្រី កែវ-វិច្ឆរា, កែវ-វិមល!, ដែលបានអនិច្ចកម្មទៅហើយនោះ!, ពួកញាតិទាំងប្រាំពីរសន្តានផង!ទាំងក្នុងសង្សារវដ្តទាំងអស់ផង! និងប្រជាពលលោកនៅក្នុងពិភពលោកទាំងមូលសូមកុំឲ្យមានពៀរនឹងគ្នាផង,ជាពិសេសប្រជាពលករអ្នកក្រីក្រមានអ្នករើសសំរ៉ាម,រើសកំប៉ុងជាដើមផងសូមអស់លោកបានសេច

ក្តីសុខសេចក្តីចំរើននិងទីបំផុត!សូមឲ្យបានរួចផុតចាកទុក្ខទាំងឡាយ ទាំងពួងទាំងអស់គ្នា! ៕

## កម្រង អត្ថបទ ធម៌ទេសនា

## មាតិកាធម៌

១- អត្ថបទធម៌ ស្តីអំពី " ខ្លឹមសារនៃការចូលវស្សា" ទំព័រ ទី ០៥

២ - អត្ថបទធម៌ ស្តីអំពី " ទាន " . . . . ១៧

៣ - អត្ថបទធម៌ ស្តីអំពី " សីល " . . . . ៣១

៤ - អត្ថបទធម៌ ស្តីអំពី " រូបកាយ " . . . . ៤៧

៥ - អត្ថបទធម៌ ស្តីអំពី " ព្រះពុទ្ធសាសនា " . . . ៦២

៦ - អត្ថបទធម៌ ស្តីអំពី " ព្រះឱវាទ បី " . . . . ៧៤

៧ - អត្ថបទធម៌ ស្តីអំពី " សតិបដ្ឋានសូត្រ " . . . ៩៧

មហាឧបាសិកា សុខ-ឈុនលី អ្នកចំណាយវិភាគទានបោះពុម្ពកាលពីលើកទី១

# បទនមស្សការ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ដង)

**នមត្ថុ រតនត្តយស្ស**

ខ្ញុំព្រះអង្គសូមលំឱនលំឱនកាយ វាចាចិត្តក្រាបថ្វាយបង្គំចំពោះប្រជុំបីនៃព្រះរតនត្រ័យគឺ ព្រះពុទ្ធរតនៈ ព្រះធម្មរតនៈនិងព្រះសង្ឃរតនៈ ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត **៦តេន សច្ចវជ្ជេន** ដោយកិរិយាពោលនូវពាក្យសច្ចនេះ **សព្វន្តរាយ និវារនត្ថុំ** ដើម្បីការពាររារាំងនូវឧបទ្រពឧបយន្តរាយទាំងឡាយទាំងពួងកុំបីឲ្យកើតមានឡើយ **សុវត្ថិ ហោតុ សព្វទា** សូមឲ្យមានតែសិរីសួស្តីជ័យមង្គលវិបុលសុខគ្រប់ប្រការកើតមានដល់លោកអ្នកស្តាប់ទាំងឡាយទាំងអ្នកសម្តែងនេះផង អស់កាលជានិច្ចនិរន្តរ៍តទៅ!។

## ខ្លឹមសារនៃការចូល-ចាំវស្សា

សាធុជនទាំងឡាយ! តាមប្រពៃណីនៃបុព្វបុរសរបស់ខ្មែរយើងពីបុរាណកាលមកថ្ងៃ១៥កើតខែអាសាឍ នៅគ្រប់វត្តអារាមក្នុងសកលពុទ្ធសាសនមណ្ឌលអស់លោកពុទ្ធបរិស័ទឧបាសក-សិកាទាំងឡាយតែងអញ្ជើញទៅប្រជុំគ្នានៅក្នុងទីវត្តអារាមប្រារព្ធធ្វើពិធីបុណ្យអបអរសាទរចំពោះការចូល-ចាំវស្សានៃព្រះភិក្ខុសង្ឃជារៀងរាល់ឆ្នាំ។ដើម្បីឲ្យបានបុណ្យកាន់តែច្រើនថែមទៀត! យើងគួរតាំងចិត្តកំណត់បុណ្យ

នេះឈ្មោះថា“បុណ្យអាសាឡ្ហបូជា”ដូច្នេះផងដោយយើងអធិដ្ឋានចិត្ត ថាធ្វើបុណ្យបូជាចំពោះថ្ងៃកំណើតនៃព្រះធម៌ និងព្រះសង្ឃផងដែរ!ពីព្រោះថ្ងៃ១៥កើតខែអាសាឍនេះ! ជាថ្ងៃដែលព្រះសម្ពុទ្ធទ្រង់ចាប់ផ្តើម សម្តែងព្រះធម៌ទេសនា ប្រោសសត្វលោកមុនដំបូងគេបង្អស់ ហៅថា “បឋមទេសនា”។ ព្រះអង្គសម្តែងព្រះធម្មចក្កប្បវត្តនសូត្រប្រោសពួក បញ្ចវគ្គីយ៍មុនគេបង្អស់ បញ្ចវគ្គីយ៍បានស្តាប់ព្រះធម៌ទេសនារបស់ព្រះ ពុទ្ធក្នុងពេលនោះព្រះកោណ្ឌញ្ញៈក៏បានសម្រេចធម៌ជាន់ខ្ពស់មុនគេជា ព្រះអរហន្តហើយបាន សូមឧបសម្បទាបួសជាភិក្ខុថ្វាយខ្លួនចំពោះព្រះ ពុទ្ធសាសនា ព្រះពុទ្ធក៏ស្តេចទ្រង់ប្រទានឯហិភិក្ខុដល់ ព្រះកោណ្ឌញ្ញៈ នាពេលនោះនិងដល់ភិក្ខុ៤រូបទៀតនៅថ្ងៃជាបន្ទាប់គឺព្រះវប្បៈ,ភទ្ទិយៈ អស្សជិ, មហានាម។ សូមបញ្ជាក់ឡើងវិញថាថ្ងៃ១៥ កើតខែអាសាឍ នេះជាឧបលក្ខិតកាលមួយ!ដ៏ឧត្តមព្រោះជាថ្ងៃកំណត់សំគាល់នូវអភិ- សម័យ៥យ៉ាងគឺៈទី១-ព្រះសិទ្ធត្ថទ្រង់ចុះចាប់បដិសន្ធិក្នុងព្រះមាតុទរ នៅព្រះជាតិចុងក្រោយនេះ!, ទី២-ទ្រង់សោយរាជសម្បត្តិ, ទី៣-ទ្រង់ ចេញសាងព្រះផ្នួស, ទី៤- ព្រះអង្គចាប់ផ្តើម! សម្តែងព្រះធម៌ទេសនា ប្រោសសត្វលោកលើកដំបូងបង្អស់! និង៥-ពន្លក បណ្តូលព្រះសង្ឃ សាវ័កក៏បានប្រសូតិឡើង នៅថ្ងៃ១៥ កើតខែអាសាឍនេះដែរ!ដោយ ព្រះអញ្ញាកោណ្ឌញ្ញៈឯហិភិក្ខុឧបសម្បទា! ជាព្រះសង្ឃទី១មុនដំបូង គេបង្អស់ក្នុងព្រះពុទ្ធសាសនាគឺជាព្រះសង្ឃរតនៈ, សូមជំរាបលោក អ្នកអំពីពាក្យថា ឯហិភិក្ខុ នេះឲ្យបានយល់ច្បាស់ថាមនុស្សដែលនឹង បានទៅជា ឯហិភិក្ខុនោះ ជាមនុស្សដែលមាននិស្ស័យខ្ពស់ណាស់! មានចិត្តដំកល់មាំក្នុងព្រះធម៌ជាន់ខ្ពស់មានចិត្តផុតស្រឡះចាកមន្ទិល ទាំងឡាយមាននីវរណធម៌ជាដើមហើយដែលព្រះសម្ពុទ្ធទ្រង់ប្រមើល មើលឃើញថាមាននិស្ស័យចាស់ក្លាល្មមទទួលឋានៈជាឯហិភិក្ខុបាន ទើបព្រះអង្គទ្រង់ព្រះប្រទានគឺជាមនុស្សធម្មតាដែលមានសក់វែងនិង

ពុកមាត់,ពុកចង្កា,មានសំលៀកបំពាក់ជាខោអាវ,ជាសំពត់ ធម្មតាជាគ្រហស្ថហ្នឹងឯង,កាលណាព្រះពុទ្ធទ្រង់ប្រទានព្រះពុទ្ធដីកាថា “ឯហិ-ភិក្ខុ!អ្នកចូរមកជាភិក្ខុចុះ!” ដូច្នេះចេញពីព្រះឱស្ឋ! ព្រះអង្គហើយអ្នកនោះឯងប្រែទៅជាមានសក់ខ្លី,បាត់ពុកមាត់ពុកចង្កាអស់ឯសំលៀកបំពាក់ក៏ប្រែទៅជាសំពត់កាសាវៈគ្របដណ្តប់ រូបកាយជាសមណៈភេទដ៏ប្រសើរភ្លាមមួយរំពេចក្រោយពីព្រះឱស្ឋព្រះអង្គពោលចប់ភ្លាម,ភេទនេះកើតមានដោយឧបនិស្ស័យឫទ្ធិតេជៈបារមីនៃព្រះពុទ្ធយ៉ាងនេះឯងនៃ!ភាពដ៏អស្ចារ្យយ៉ាងនេះឯងដែលហៅថា“ឯហិភិក្ខុ”នោះ,តទៅនេះ

## អំពី“បុព្វហេតុ”នៃការ“ចូល-វស្សា”

នៅថ្ងៃពេញបូណ៌មីមួយព្រះសម្មាសម្ពុទ្ធមួយអន្លើដោយព្រះភិក្ខុសង្ឃចំនួន១២៥០រូបបានស្តេចយាងនិងនិមន្តទៅកាន់ព្រះរាជនិវេស-នដ្ឋាននៃព្រះបាទពិម្ពិសារនាក្រុងរាជគ្រឹះដើម្បីទទួលភត្ត។ រីឯព្រះបាទពិម្ពិសារ,ព្រះអគ្គមហេសីវេទេហី, ព្រះរាជបុត្តអជាតសត្តុកុមារនិងភ្ញៀវរបស់ព្រះអង្គចំនួន៦ពាន់នាក់បិតនៅក្នុងព្រះរាជដំណាក់ត្រៀមរៀបចំចាំក្រាបថ្វាយបង្គំព្រះពុទ្ធព្រមទាំងព្រះភិក្ខុសង្ឃសាវ័ក! ។ លុះព្រះពុទ្ធស្តេចយាងចូលទៅដល់ហើយ! ព្រះភិក្ខុសង្ឃទាំងឡាយក៏គង់នៅលើអាសនៈដែលគេរៀបចំទុកថ្វាយយ៉ាងផ្ចិតផ្ចង់! ឯព្រះពុទ្ធស្តេចគង់នៅលើអាសនៈកិត្តិយសចំកណ្តាលរោងព្រះពន្លា។ពេលដែលព្រះសាស្តាស្តេចគង់ចុះទើបព្រះបាទពិម្ពិសារទ្រង់អញ្ជើញភ្ញៀវទាំងឡាយ អង្គុយចុះដែរ។ ព្រះបាទពិម្ពិសារនិងព្រះឧរុវេលកស្សបៈគង់នៅទាំងសង្ខាងព្រះពុទ្ធ ។ ព្រះបាទពិម្ពិសារព្រះរាជវង្សានុវង្សនិងភ្ញៀវទាំងឡាយបានអង្គាសចង្ហាន់ព្រះភិក្ខុសង្ឃដែលមានព្រះពុទ្ធទ្រង់ជាព្រះប្រធានដោយខាទនិយៈភោជនិយាហារដ៏ឧត្តមនិងដោយផ្ចិតផ្ចង់បំផុត! ។ ព្រះរាជាទ្រង់បំរើព្រះពុទ្ធដោយផ្ទាល់ឯព្រះនាងវេទេហីនិងពួកស្រីស្នំព្រមទាំងភ្ញៀវទាំងឡាយបំរើព្រះភិក្ខុសង្ឃទាំង១២៥០អង្គដោយសេចក្តីគោរព

បំផុត។ ភ្ញៀវទាំង៦ពាន់របស់ព្រះបាទពិម្ពិសារមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការទទួលភត្តដ៏ស្ងៀមស្ងាត់ប្រកបដោយឥន្ទ្រីយ៍សំវរដ៏ល្អប្រសើរ និងមានរបៀបរៀបរយបំផុត! របស់ភិក្ខុទាំងឡាយនោះណាស់។ បន្ទាប់ពីព្រះសង្ឃទទួលភត្តរួចមួយស្របក់មក ព្រះបាទពិម្ពិ-សារបានអារាធនាព្រះសាស្តាប្រទានព្រះធម៌ទេសនា,ព្រះពុទ្ធទ្រង់សំដែងព្រះធម៌ទូន្មានស្តីអំពីសិក្ខាបទ៥នៃនិច្ចសីលឬបញ្ចសីលាដែលជាមាគ៌ានាំឲ្យកើតសេចក្តីសុខសុភមង្គលក្នុងក្រុមគ្រួសារផង! ក្នុងសង្គមជាតិផងនិងលើពិភពលោកទាំងមូលផង!ព្រោះសីល៥ជា“មនុស្សធម៌”និងជា“រូបមន្ត”នៃសន្តិភាពពិតៗ។ លុះស្តាប់ព្រះធម៌ទេសនាចប់ ព្រះបាទពិម្ពិសារកាន់តែមានសេចក្តីជ្រះថ្លាខ្លាំងក្លាណាស់!ចង់តែស្តាប់ធម៌ហើយទៀតស្តាប់ឲ្យបានច្រើនដង និងចង់សិក្សាព្រះធម៌ដោយផ្ទាល់ពីព្រះពុទ្ធផង!។ ព្រះរាជាទ្រង់រិះរកមធ្យោបាយធ្វើយ៉ាងណាឲ្យ ព្រះបរមសាស្តាស្តេចបានគង់នៅជិតព្រះអង្គ ព្រះបាទពិម្ពិសារ!ទ្រង់ព្រះតម្រិះបន្តិច រួចក៏ក្រោកឈរឡើងក្នុងកណ្តាលមហាសន្និបាត! ហើយទ្រង់ក៏ប្រកាសដ៏ឱឡារិកថាៈ បពិត! ព្រះសម្មាសម្ពុទ្ធដ៏ចំរើន! ខ្ញុំព្រះអង្គមានឧទ្យានមួយ ស្ថិតនៅចម្ងាយប្រមាណជា៣គីឡូមែត្រនៅទិសខាងជើងនៃក្រុងរាជគ្រឹះនេះ មានព្រៃឫស្សីធំក្រាស់ និងស្រស់បំព្រងជាកន្លែងដ៏ស្ងប់ស្ងាត់! មានខ្យល់អាកាសល្អត្រជាក់ស្រួល! មានសត្វកំប្រុកពណ៌ក្រហមចាស់អាស្រ័យនៅច្រើន!ខ្ញុំព្រះអង្គសូមថ្វាយវេឡុវន័ឧទ្យាននេះចំពោះព្រះភិក្ខុសង្ឃ ដែលមានព្រះដ៏មានព្រះភាគជាព្រះប្រធាន ដើម្បីនឹងធ្វើជាអារាមសម្រាប់បង្រៀនព្រះធម៌! ដល់ព្រះភិក្ខុសង្ឃ! សូមព្រះបរមសាស្តា មេត្តាប្រោសទទួលនូវ“ឧទ្យានវេឡុវន័” នេះអំពីខ្ញុំព្រះអង្គដោយព្រះហឫទ័យអនុគ្រោះឲ្យទាន!។ ព្រះពុទ្ធទ្រង់ព្រះតម្រិះ! ថា : “ឱ!នេះជាលើកទី១ហើយដែលសង្ឃគណៈបានទទួលនូវព្រះរាជទានជាដីសម្រាប់ កសាង“វត្ត”ទើបព្រះបរមសាស្តា ទ្រង់ស្តេចហាក់ដូចជា

ងក់ព្រះសិរទទួលនូវព្រះរាជទានដ៏មហាសប្បុរសរបស់ព្រះរាជាដោយព្រះភ័ក្ត្រញញឹមជាតុណ្ហីភាព។ ព្រះបាទពិម្ពិសារទ្រង់រំភើបព្រះហទ័យយ៉ាងខ្លាំងក៏ឲ្យគេយកទឹកដម្កល់ក្នុងកុណ្ឌី( ផ្តិលមាស )មកថ្វាយរួចព្រះរាជាទ្រង់លើកផ្តិលមាសចាក់ទឹកស្រោចស្រពលើព្រះហស្ថទាំងគូ! នៃព្រះសាស្តា!ហើយទ្រង់ប្រកាសដ៏ឱឡារិកថា"បពិត្រ! ព្រះបរមសាស្តាដ៏ចំរើន!ខណៈដែលវារីដ៏ថ្លាត្រជាក់ល្ហឹម!នេះចាក់ស្រោចស្រពលើព្រះហស្តព្រះអង្គហើយ!វេឡុវន័ឧទ្យានទាំងមូលក៏ត្រូវបានវេរថ្វាយជាកម្មសិទ្ធិរបស់ព្រះភិក្ខុសង្ឃដែលមានព្រះពុទ្ធជាព្រះប្រធានជាស្ថាពរដែរ។ លុះចប់កម្មវិធីនេះហើយ!បន្ទាប់មកព្រះពុទ្ធនិងព្រះថេរភិក្ខុជាច្រើនរូបបានស្តេចយាង-និមន្ត!ចូលទៅទស្សនាព្រៃឫស្សីដែលមានទំហំ១០០ហិកតា, មានឫស្សីគ្រប់ប្រភេទនោះ!។ នៅចំកណ្តាលព្រៃឫស្សីនោះមានបឹងមួយដ៏ធំមានទឹកថ្លាឆ្វង់ដ៏ត្រជាក់! មើលឆ្លុះដល់បាទដី ឈ្មោះ "កាឡានទិកៈ"ដែលព្រះភិក្ខុសង្ឃអាចចុះស្រង់ដងយកមកបោកគក់ស្បង់ចីវរ!និងនិមន្តដើរចង្ក្រមជុំវិញបានយ៉ាងស្រួលព្រះថេរកោណ្ឌញ្ញៈឧរុវេលកស្សបៈ, និងព្រះសារីបុត្តពេញព្រះទ័យព្រៃឫស្សីនោះណាស់ភិក្ខុទាំងឡាយក៏ចាប់ផ្តើមរៀបចំកសាងវត្តអារាមនៅទីនោះតែម្តង!។ គាប់ជួនពេលនោះរដូវវស្សាក៏ចូលមកដល់ភិក្ខុមួយចំនួនបានចូលទៅក្រាបបង្គំទូលថ្វាយព្រះបរមសាស្តាថា "បពិត្រព្រះអង្គដ៏ចំរើន! ពេលដែលខ្ញុំព្រះអង្គទាំងឡាយត្រាច់ទៅបិណ្ឌបាត្រមានអ្នកស្រុកអ្នកភូមិខ្លះបានពោលពាក្យរិះគន់ថាយីពួកសមណៈសក្យបុត្តមិនសមបើដើរបិណ្ឌបាត្រក្នុងវស្សាន្តរដូវដើរជាន់ស្មៅស្រស់,ជាន់សត្វជន្លេន និងសត្វល្អិតផ្សេងៗដែលចេញមកពីដីសើមនៅរដូវភ្លៀងធ្លាក់នេះ! ដូច្នេះសោះ!។ ព្រះពុទ្ធទ្រង់ព្រះសណ្តាប់ហើយទើបទ្រង់ព្រះតម្រិះថា"ឱ!តថាគតមិនទាន់បានបញ្ញត្តនូវការចូលវស្សានេះដល់ភិក្ខុទាំងឡាយនៅឡើយ" ។ ទើបព្រះអង្គទ្រង់ប្រជុំភិក្ខុទាំងឡាយហើយទ្រង់អនុញ្ញាតថា"ម្នាលភិក្ខុ

ទាំងឡាយ! នៅរដូវវស្សាអាកាសធាតុមិនសូវល្អសម្រាប់ធ្វើដំណើរទេ ភិក្ខុទាំងឡាយ!ក៏ត្រូវរកកន្លែងរៀនសូត្រព្រះធម៌រួមគ្នានៅក្នុងរដូវភ្លៀងនេះដែរ!ម្នាលភិក្ខុទាំងឡាយ!ចាប់តាំងពីវស្សានរដូវនេះទៅ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយចូលកាន់វស្សាជាផ្លូវការហើយ! **អនុជានាមិ ភិក្ខវេ វស្សំ ឧបគន្តុំ** នៅពេលចូលកាន់វស្សានោះអ្នកសូមឲ្យឧបាសកឧបាសិកានៅតាមដំបន់ដែលអ្នកគង់នៅនោះឲ្យគេជួយផ្គត់ផ្គង់ចង្ហាន់បិណ្ឌបាត្របាន។នែ!បុព្វហេតុប៉ុណ្ណឹងដែលនាំឲ្យមានការចូលចាំវស្សាជាប្រពៃណីរបស់ភិក្ខុ-សាមណេរទាំងឡាយ នៅក្នុងព្រះពុទ្ធសាសនារហូតមកដល់សព្វថ្ងៃនេះ។ ការចូលវស្សាមានពីដង ថ្ងៃចូលវស្សាទី១មុនហៅថា"បុរិមិកាវស្សា"ពីថ្ងៃ១រោចខែអាសាធ ដល់ថ្ងៃ១៥ កើតខែអស្សុជ,ព្រះពុទ្ធទ្រង់មានព្រះអធ្យាស្រ័យអនុគ្រោះដល់ភិក្ខុណាដែលមានភារកិច្ចអ្វីចាំបាច់នៅខាងក្រៅវត្តរបស់ខ្លួនដែលមិនអាចចូលវស្សានៅថ្ងៃលើកទី១បានព្រះអង្គទ្រង់អនុញ្ញាតឲ្យចូលជាលើកទី២បាន ពីថ្ងៃ១រោចខែស្រាពណ៍ដល់ថ្ងៃ១៥កើតខែកត្តិកហៅ"បច្ឆិមិកាវស្សា"។ តទៅ ខ្ញុំព្រះករុណាសូមធ្វើការទាក់ទាញអារម្មណ៍-ស្មារតីរបស់លោកម្ចាស់ភិក្ខុសាមណេរអង្គខ្លះមួយចំនួនដែលមិនបានជាយកចិត្តទុកដាក់ពីខ្លឹមសារនៃការចូលចាំវស្សានេះគឺបើគេសូត្របាលីចូលវស្សា ក៏សូត្របាលីចូលវស្សានឹងគេទៅ,បើគេសូត្របាលីបវារណាចេញវស្សាក៏សូត្របាលីបវារណាចេញវស្សានឹងគេទៅ,ឥតបានដឹងថាអត្ថន័យខ្លឹមសារនៃការចាំវស្សានោះយ៉ាងណាឡើយ ដូចជាសត្វកង្កែបដែលនៅក្រោមផ្កាឈូកក្នុងបឹងហើយមិនដឹងថាក្លិនផ្កាឈូកនោះក្រអូប-ឈ្ងុយយ៉ាងណាឡើយ( ខ្ញុំករុណាសូមអធ្យាស្រ័យផងដែរចំពោះលោកម្ចាស់ភិក្ខុសាម-ណេរជាពហុស្សូត)សូមលោកម្ចាស់ទាំងឡាយមេត្តាយល់អំពីខ្លឹមសារនៃការចាំវស្សាដូចតទៅ,សូមគិតថាក្នុង១ឆ្នាំមាន១២ខែរួចរយៈពេល ៩ខែគឺពី១រោចខែអស្សុជ.ដល់១៥កើតខែអាសាធ,ជារយៈពេលដែល

ព្រះពុទ្ធទ្រង់អនុញ្ញាតឲ្យភិក្ខុ-សាមណេរ និមន្តដើរហើរទៅកាន់ទីណាបានតាមចិត្ត,ទៅទីណា១សប្តាហ៍ក្តី,១ខែ២ខែក្តី,ទៅសួរសុខទុក្ខញាតិញោមក្តី, -សហធម្មិកៈផងគ្នាក្តី, -ទៅបំពេញការងារសង្ឃគណៈក្តី ឬក៏ចេញទៅបរទេសណាក្តីបានតាមប្រាថ្នា, ប៉ុន្តែនៅពេលធ្វើដំណើរនោះៗជួនកាល ក៏មិនបានគោរពធម៌វិន័យឲ្យបានល្អត្រឹមត្រូវដ៏ប្រសើរទេ!, ម្ល៉ោះហើយការខ្វះចន្លោះតែងតែមានខ្លះមិនខានដូច្នេះបានជាក្នុងរយៈពេលចូលចាំវស្សា៣ខែនេះព្រះពុទ្ធទ្រង់បញ្ញត្តឲ្យភិក្ខុ-សាមណេរស្ថិតនៅហ្នឹងមួយកន្លែងដើម្បីសិក្សារៀនសូត្រធម៌វិន័យនិងសំអាតចិត្តត្រួតពិនិត្យការប្រព្រឹត្តិរបស់ខ្លួនកន្លងមកគឺដូចជាឲ្យភិក្ខុ-សាមណេរអង្គុយទល់មុខនឹងកញ្ចក់ឆ្លុះបញ្ចាំងមើលឲ្យឃើញច្បាស់ថាក្នុងរយៈពេល៩ខែខាងក្រៅវស្សានោះតើខ្លួនអាត្មាអញភិក្ខុ-សាម ណេរមួយរូបៗមានបានប្រព្រឹត្តធ្វើអំពើអ្វីខ្លះដែលខុសឆ្គងនឹងវិន័យបញ្ញត្តដែរ! ឬទេ? បើឃើញថាមានខុសឆ្គងកន្លែងណាគប្បីធ្វើការកែតម្រូវឡើងវិញ,ប្រសិនបើឃើញថានៅខ្វះចន្លោះកន្លែងណា?ត្រូវខំព្យាយាម បំពេញបន្ថែមគឺខំរៀនសូត្រជាពិសេសក្នុងឥន្ទ្រីយ៍សំវរសីលមានសតិសំវរៈជាដើមឲ្យសមឋានៈខ្លួនជាសមណៈសក្យបុត្ត!។ ដែលសំខាន់បំផុតត្រូវយកអភិណ្ហបច្ចវេក្ខណៈ១០ប្រការមកធ្វើជាកញ្ចក់ឆ្លុះនូវកំហុស, (អភិណ្ហបច្ចវេក្ខណៈមាននៅក្នុងសៀវភៅភិក្ខុបាតិមោក្ខស្រាប់ទំព័រ១៣០) ។ ឯកញ្ចក់ ទី១= **វេវណ្ណិយម្ហិ អជ្ឈុបគតោ** ត្រូវរំពឹងគិតថាអាត្មាអញមានភេទផ្សេងពីគ្រហស្ថហើយអាការកិរិយាណាជារបស់សមណៈអាត្មាអញត្រូវតែប្រព្រឹត្តតាមអាការកិរិយានោះ។ ទី២- **បរប្បដិពទ្ធា មេ ជីវិកា** ការចិញ្ចឹមជីវិតរបស់អាត្មាអញរស់ដោយសារអ្នកដទៃ ដូច្នេះអាត្មាអញគួរធ្វើខ្លួនឲ្យគេចិញ្ចឹមងាយ!។ ទី៣- **អញ្ញោ មេ អាកប្បោ ករណីយោ** អាត្មាអញត្រូវធ្វើអាកប្បកិរិយាអំពើដោយកាយ,វាចាឲ្យសមរម្យផ្សេងពីគ្រហស្ថ ទី៤- **កច្ចិ នុ ខោ អត្តាសីលតោ ន ឧបវទតិ** ត្រូវពិចារណាថាចិត្តរបស់

អាត្មាអញមិនតិះដៀលខ្លួនឯង ព្រោះតែសីលមិនបរិបូណ៌ទេឬ? ទី៥- **កច្ចិ នុ ខោ មំ អនុវិច្ចវិញ្ញូ សព្រហ្មចារី សីលតោ ន ឧបវទន្តិ** ត្រូវគិតថាពួកសព្រហ្មចារីជាអ្នកប្រាជ្ញពិចារណាហើយមិនតិះដៀលអាត្មាអញព្រោះតែសីលមិនបរិបូណ៌ទេឬ? ទី៦- **សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភា វោ** ត្រូវពិចារណាថាអាត្មាអញគង់តែព្រាត់ប្រាសនិរាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ពេញចិត្តមិនខាន!។ ទី៧ = **កម្មស្សកោម្ហិ កម្មទាយាទោ** ត្រូវពិចារណាថាអាត្មាអញមានកម្មជារបស់ខ្លួនមានកម្មជាអ្នកឲ្យផលអាត្មាអញធ្វើនូវកម្មណាជាកម្មល្អក្តីអាក្រក់ក្តីអាត្មាអញនឹងត្រូវតែជាអ្នកទទួលនូវផលនៃកម្មនោះៗជាពិតប្រាកដ ។ ទី៨- **កថម្ភូតស្ស មេ រត្តិន្ទិវា វីតិបតន្តិ** ពិចារណាថាថ្ងៃនិងយប់ចេះតែកន្លងទៅៗតើអាត្មាអញបានធ្វើអ្វីខ្លះជាទីពឹងឬនៅសម្រាប់អនាគត?។ ទី៩-**កច្ចិ នុ ខោ ហំ សុញ្ញាគារេ អភិរមាមិ** ត្រូវពិចារណាថាតើអាត្មាអញមានត្រេកអរក្នុងទីកន្លែងដ៏ស្ងាត់ជាទីអប់រំចិត្តដែរឬទេ!។ កញ្ចក់ទី១០- **អត្ថិ នុ ខោ មេ ឧត្តរិមនុស្ស ធម្មា** ត្រូវពិចារណាថាអាត្មាអញបានត្រាស់ដឹងធម៌ជាន់ខ្ពស់ណាមួយដើម្បីកំចាត់បង់នូវកិលេសណាមួយដែរឬទេ ទាំង១០ប្រការនេះ ជាកញ្ចក់ឆ្លុះមើលខ្លួនឯង! របស់ភិក្ខុ-សាមណេរទាំងឡាយក្នុងការចាំវស្សាអស់ត្រីមាសនោះ!,ពុទ្ធបរិស័ទជាឧបាសកឧបាសិកាលោកបានយល់អំពីខ្លឹមសារនៃការចាំវស្សា របស់ភិក្ខុសង្ឃថាមានគុណានុភាពដ៏ប្រសើរយ៉ាងនេះ ទើបបានជាលោកខំចំណាយធនធានបេះពីមាត់ពីកជាវជាត្រ័យចីវរ,សាដកជាដើមធ្វើជា"អង្គកឋិន"ដង្ហែយកទៅវេរប្រគេនព្រះភិក្ខុសង្ឃនៅពេលចេញវស្សាគ្រប់វត្តស្ទើរតែចេញវស្សាមិនទាន់ផង! ដោយសារតែចង់បានបុណ្យច្រើន ពីព្រោះ កឋិន ជាកាលទាន!, បើធ្វើបានបុណ្យច្រើនណាស់កឋិនក្នុង១ឆ្នាំមានរយៈកាលតែ២៩ថ្ងៃប៉ុណ្ណោះ។ព្រះភិក្ខុសង្ឃលោកអ្នកក្រាលគ្រងអ្នកអនុមោទនាបានអានិសង្សច្រើនទាំងលោកអ្នកធ្វើអង្គកឋិននោះក៏បាន

អានិសង្សច្រើនទាំងអស់គ្នា។អាស្រ័យហេតុនោះបានជាខ្ញុំព្រះករុណាសូមអង្វរព្រះទ័យភិក្ខុ-សាមណេរចំនួនខ្លះដែលមិនបានចាប់អារម្មណ៍និងមិនមានសតិសម្បជញ្ញៈល្អនៅឡើយសូមខំបំពេញនូវគុណធម៌ដូចពោលខាងលើនេះឲ្យបានល្អប្រសើរដើម្បីឲ្យសមឋានៈខ្លួនជាសមណៈសក្យបុត្តអ្នកទ្រទ្រង់ព្រះពុទ្ធសាសនាដោយផ្ទាល់គ្រប់ព្រះអង្គកុំបីខានកុំឲ្យវត្ថុសម្ភារៈលោកិយ៍មាន ម៉ាញ៉េ ទូរទស្សន៍ទូរសព្ទ័ដែជាដើមវាអូសទាញឲ្យភ្លើតភ្លើនភ្លេចខ្លួនថាខ្លួនជាអ្នកបួសនោះឲ្យសោះព្រោះវាទាំងអស់ហ្នឹងហើយដែលជាបច្ច័យធ្វើឲ្យព្រះពុទ្ធសាសនាចុះអាប់ឱននោះសូមលោកម្ចាស់ទាំងឡាយមេត្តាគិតឲ្យបានល្អិតល្អន់ម៉ត់ចត់មែនទែនបែបនេះទើបប្រសើរ! សូមលោកម្ចាស់ទាំងឡាយមេត្តាយល់ពីតួនាទីរបស់ខ្លួនឲ្យបានច្បាស់បែបនេះហើយ ខំបំពេញកុសលធម៌ឲ្យបានល្អប្រសើរជានិច្ចនិរន្តរ៍តទៅឲ្យសមជាស្រែបុណ្យដ៏មានជីវជាតិល្អប្រសើរសម្រាប់ពុទ្ធបរិស័ទសាបព្រោះពូជឲ្យបានផលល្អទៅផងនិងជាកុសលផលបុណ្យសម្រាប់ខ្លួនឯងផ្ទាល់ខ្លួនមួយរូបៗផង“ការចូលវស្សាចប់”។

ប៉ុន្តែនៅពេលបញ្ចប់នេះ ខ្ញុំសូមប្រមូលផ្តុំនូវមហាកុសលដែលកើតអំពីការសំដែងនិងការស្តាប់ប្រកបដោយសោមនស្សសហគតចិត្តដ៏ល្អប្រសើរទាំងអស់គ្នានេះធ្វើជាបូជនិយវត្ថុដ៏ឧត្តមមួយយើងខ្ញុំសូមជូនពរបវរសួស្តីជ័យមង្គលវិបុលសុខគ្រប់ប្រការ ប្រគេន ថ្វាយ ជូនចំពោះដួងវិញ្ញាណថ្មីមហាវីរបុព្វបុរសអ្នកស្នេហាជាតិគ្រប់ជំនាន់របស់យើងដែលលោកបានទទួលមរណភាពឬពលីជីវិតដើម្បីជាតិមាតុភូមិនិងសាសនាទាំងព្រះមហាក្សត្រអង្គណា! ដែលទ្រង់ប្រកបដោយ ទសពិធរាជធម៌តាំងពីអតីតកាលដ៏យូរលង់!ណាស់ទៅហើយក្តី ពេលបច្ចុប្បន្ននេះ ក្តីដែលលោកបានស្ថាបនាប្រទេសជាតិ-មាតុភូមិ ឲ្យមានវិសាលភាពដ៏ទូលំទូលាយជាមហានគរក្នុងសម័យនោះហើយលោកបានបន្សល់ទុកនូវស្នាដៃជាទំនៀមទំលាប់ ដំបូន្មានប្រពៃណីដ៏ល្អៗ និងកេតនភ័ណ្ឌដ៏

ប្រណីតៗប្រសើរថ្លៃថ្លាដ៏ច្រើនអនេកមានប្រាង្គណ៍ប្រាសាទនគរវត្តជាដួងព្រលឹង និងជានិមិត្តរូបនៃប្រជាជាតិនិងប្រទេសជាតិយើង ជាដើមទុកដល់យើងសព្វថ្ងៃ ដែលអន្តរជាតិនៅក្នុងពិភពលោកទាំងមូលក៏តែកោតសរសើរគេស្ញប់ស្ញែង នូវស្នាដៃដ៏ឧត្តមស៊ីមស្ពែ ជាស្ថាបត្យកម្មដ៏រស់រវើករបស់ខ្មែរយើងនេះផងដែររហូតមកដល់ពេលថ្មីៗមុននេះបន្តិចបន្តិចមានព្រះអាចារ្យហែមចៀវ,លោកក្រឡាហោមគង់,លោកតាឃ្លាំង-មឿង,លោក សក្តិ ៣ អ៊ុំ ជាដើម, រហូតមកដល់សម្តេចព្រះសង្ឃរាជជួន-ណាត,សម្តេចព្រះសង្ឃរាជ ហួត-តាត, ហើយដែលសម្តេចព្រះសង្ឃរាជជួន-ណាត,ហួត-តាតព្រះអង្គមានប្រយោជន៍ចំពោះព្រះពុទ្ធពុទ្ធសាសនាច្រើនណាស់,ប្រសិនបើអស់លោកអ្នកសប្បុរសបានអានសៀវភៅមួយដែលមានចំណងជើងថា"កល្យាណមិត្តរបស់ខ្ញុំផងទៀតនោះទើបអស់លោកនឹងបានឃើញពីសកម្មភាពនៃស្នាព្រះហស្តរបស់សម្តេចជាក់ច្បាស់នឹងភ្នែក។សម្តេចបានរៀបចំធម៌វិន័យដែលមានការល្អៀងឃ្លៀងឃ្លាតខ្លះឲ្យបានល្អប្រសើរឡើងវិញ,សម្តេចបានប្រែគម្ពីរព្រះត្រ័យបិដកពីភាសាបាលីមកជាភាសាខ្មែរយើងជាមួយក្រុមជំនុំប្រែព្រះត្រ័យបិដកដទៃទៀតជាច្រើនរូបផងដែរប្រើថេរវេលាអស់រយពេល៤០ឆ្នាំគត់ (ពីគ.ស.១៩២៩ដល់១៩៦៩) ទើបបានប្រែចប់សព្វគ្រប់ទាំង១១០ភាគ,ជាមហាវីរិយភាពដ៏ធំធេងណាស់! ជាមហាពលីកម្មដ៏អស្ចារ្យណាស់! គួរឲ្យស្ងើចសរសើរណាស់! គួរឲ្យគោរពព្រះគុណនៃព្រះមហាវីរបុព្វបុរសទាំងអស់នោះណាស់! ។= នៅពេលប្រែចប់ឆ្នាំគ.ស.១៩៦៩នោះ, សម្តេចព្រះសង្ឃរាជ ជួន-ណាត បានដឹកនាំព្រះសង្ឃនិងពុទ្ធបរិស័ទគ្រប់វត្តទាំងអស់ ក្នុងប្រទេសកម្ពុជាទាំងមូល ឲ្យរៀបចំធ្វើបុណ្យឆ្លងគ្រប់វត្តធំដុំគគ្រឹកគគ្រេងណាស់!ហើយបុណ្យនេះគួរចាត់ទុកថាជាបុណ្យ"ឆដ្ឋសង្គាយនា,គឺសង្គាយនាទី៦"ផង ពីព្រោះបណ្តាប្រទេសអ្នកកាន់ព្រះពុទ្ធសាសនានៅក្នុងពិភពលោកនេះ មាន

តែប្រទេសខ្មែរយើងមួយគត់ ដែលបានប្រែគម្ពីរព្រះត្រៃបិដកចប់មុនគេ ហើយមានប្រទេសគេដទៃមកសុំចម្លងពីយើងផង,ការណ៍នេះ,ខ្មែរយើងមានមោទនភាពណាស់!សម្តេចបាននិពន្ធក្បួនច្បាប់ជាច្រើនទុកដល់បច្ឆាជនតាជនខ្មែរយើងជំនាន់ក្រោយៗ! ជាពិសេសបំផុតនោះគឺ " វចនានុក្រមខ្មែរ" រហូតដល់បានព្រះនាមថា: "ព្រះអគ្គមហាបណ្ឌិត" អក្សរសាស្ត្រខ្មែរទៀតផង ព្រមទាំងមានគោរម្យងារមួយផ្សេងទៀតថា "ព្រះអភិធជៈមហារដ្ឋគុរុ" អំពីរដ្ឋាភិបាលនៃប្រទេសភូមាទៀតផង ពីព្រោះភូមាគេរកអ្នកប្រាជ្ញឲ្យមានសមត្ថភាពល្មមទទួលឋានន្តរសក្តិ ដ៏ខ្ពស់ផុតថ្នាក់របស់គេនេះមិនបានគេឃើញតែសម្តេចព្រះសង្ឃរាជជួន-ណាតនេះទើបមានសមត្ថភាពល្មមទទួលនូវឋានន្តរសក្តិរបស់គេនេះទើបបានជា គេថ្វាយមកសម្តេចតែម្តង។ រហូតមកដល់សម្តេច ប៉ុណ្ណ-សុម្ភាជ,ព្រះឧត្តមមុនី អ៊ុំ-ស៊ូ,ព្រះភិក្ខុមហាវិរិយបណ្ឌិតោប៉ាង-ខាត់,ព្រះភិក្ខុធម្មបាលខៀវ-ជុំ,ព្រះសិរីសោភ័ណកឹម-តូ,សម្តេចមហាឃោសានន្ទ វ៉ា-យ៉ាវ ជាដើម.ព្រមទាំងពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថដែលពួកទមិឡអន្សត្ថិរិយ៍ឥតសាសនាគេបានមកគ្រប់គ្រងប្រទេសខ្មែរអស់រយៈពេលជាង៣ឆ្នាំ ហើយគេបានសម្លាប់ដោយ អយុត្តិធម៌នោះ សូមដួងវិញ្ញាណនៃបុព្វបុរសទាំងអស់នោះ បានទទួលនូវមហាកុសលនេះបានសោយនូវសម្បត្តិសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតម្យ៉ាងទៀតសូមជូនមហាកុសលនេះចំពោះដួងវិញ្ញាណនៃបុព្វបុរសរបស់យើងទាំងអស់គ្នាផ្ទាល់ដែលកំពុងសំដែងនិងកំពុងស្តាប់នូវព្រះធម៌ហ្នឹង!សូមលោកបានទទួលនូវមហាកុសលនេះដោយឲ្យបានសោយនូវសម្បត្តិសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ហើយដោយអំណាចផលានិសង្សនៃមហាកុសលនេះ សូមបានជាបច្ច័យផ្តល់នូវសុភមង្គលវិបុលសុខ សុខក្សេមក្សាន្តក្នុងសន្តានចិត្តស្ថិតក្នុងអចលស្សទ្ធាក្នុងព្រះពុទ្ធសាសនានៃយើងខ្ញុំទាំងអស់គ្នាគ្រប់ៗគ្នា និងរកស៊ីមានបានកើតកាលវាលគុម្ពត្រជាក់ត្រ

ជំសមប្រកបជួបប្រទះតែសព្វសាធុការពរបវរសួស្តីជ័យមង្គល៥ប្រការ គឺអាយុ វណ្ណៈ សុខៈពលៈនិង បដិភាណៈ អស់កាលជានិច្ចនិរន្តរ៍ ជាពិ-សេសជូនពរប្រជាពលករក្រីក្រមានអ្នករើសសំរ៉ាម, រើសកំប៉ុង,ជាដើម សូមមហាកុសល ! នេះជួយឲ្យអ្នកឆាប់បានរួចផុតពីជីវភាពដ៏ទន់ទាប នោះទៅ!មួយចំណែកទៀតសូមជូនមហាកុសលនេះចំពោះទៅប្រជាពលលោកនៅលើពិភពលោកនេះទាំងមូលសូមកុំមានពៀរនឹងគ្នាសូម មានតែចិត្តស្រឡាញ់រាប់អានមនុស្សដូចគ្នាជាភាតរៈ ប្រកបដោយចិត្ត មានមេត្តា,មានករុណា,សន្តោស,ប្រោសប្រណីដល់គ្នានិងគ្នា ទៅវិញ ទៅមកដោយគិតឃើញថាយើងមានជាតិជាមនុស្សជាតិដូចគ្នាចង់បាន នសេចក្តីសុខដូចគ្នាចង់រស់នៅមានសេរីភាពដូចគ្នាទាំងអស់គ្នាហើយ ជាពិសេសតាមបំណងរបស់អ្នកសំដែងចង់តែសូមអង្វរ“មេអ្នកដឹកនាំ” ប្រទេសគ្រប់ប្រទេសទាំងអស់!នៅលើពិភពលោកនេះទាំងមូល មេត្តា ចាប់ដៃគ្នាដោយមេត្រីភាពដ៏ស្មោះអស់ពីដួងចិត្ត! ហើយនាំគ្នាខំដោះ ស្រាយបញ្ហាពិភពលោក ដោយ“សន្តិវិធី”វិញ សូមមេត្តាបោះបង់ការ ប្រហារគ្នាការប្រល័យគ្នាទៅ!ព្រោះទាំងអស់ហ្នុងសុទ្ធតែជាមាគ៌ាឆ្ពោះ ទៅរកវិនាសកម្មទាំងអស់!ហើយមិនមានទីបំផុតឡើយ! គឺមានតែធម៌ “អហឹង្សា”របស់ព្រះពុទ្ធទេ,មានតែ“យុត្តិធម៌”ទេ,ទើបជាមាគ៌ាឆ្ពោះទៅ រក“សន្តិភាព”ពិតៗជូនប្រជាពលលោកនៅលើដុំពិភពលោកនេះទាំង មូលបានយ៉ាងពិតប្រាកដនោះ! នេះជាសច្ចៈធម៌! ជាយុត្តិធម៌ និងជា មាគ៌ាដ៏ប្រសើរបំផុតក្នុងការដឹកនាំ!។**អយំ សទ្ធេមេន សម្មតា** ព្រះធម៌ ទេសនាដែលបានសំដែងមកនេះ ចប់ដោយសង្ខេបប៉ុណ្ណោះឯង ឯវំ ៕